# ច្បាប់ និងការផ្សាយពាណិជ្ជកម្មលក់ផលិតផល ឬសេវា

កម្ពុជា តាមរដ្ឋធម្មនុញ្ញ ប្រកាន់របបសេដ្ឋកិច្ចទីផ្សារសេរី (មាត្រា ៥៦)។ ប្រជាពលរដ្ឋ អាចធ្វើជំនួញ ហើយអាចធ្វើពាណិជ្ជកម្ម ដើម្បីទាក់ទាញ អតិថិជន មកទទួលទិញសេវា និងផលិតផលរបស់ខ្លួន។ តើច្បាប់ បទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានអ្វីខ្លះ ចែងពាក់ព័ន្ធនឹងបញ្ហាផ្សព្វផ្សាយពាណិជ្ជកម្មនេះ?

ច្បាប់ទាមទារព័ត៌មានអប្បបរមា សម្រាប់អ្នកប្រើប្រាស់ (មាត្រា ២៣ និង ២៤ នៃច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ ឆ្នាំ ២០១៩)។ ក្រុមហ៊ុន ឬបុគ្គល ត្រូវបង្ហាញ ប្រភេទ ចំណាត់ថ្នាក់ សុវត្ថិភាព បរិមាណ ប្រភពដើម មុខងារប្រើប្រាស់ ការថែទាំ សមាសធាតុផ្សំ ការរចនា ការដំឡើង វិធីប្រើ ថ្លៃ ការវេចខ្ចប់ ការផ្សព្វផ្សាយ ឬការផ្គត់ផ្គង់ កាលបរិច្ឆេទផលិត និងកាលបរិច្ឆេទផុតកំណត់ការប្រើប្រាស់ ព័ត៌មានអំពីការផលិត ឬ ព័ត៌មានដែលទាក់ទងនឹងការផ្គត់ផ្គង់ទំនិញឬសេវា។ ព័ត៌មានទាំងនេះ ត្រូវធ្វើឡើងជាភាសាខ្មែរ (មាត្រា ២៧)។

និយាយបញ្ច្រាសមកវិញ បើផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ ដែលមានលក្ខណៈភូតកុហក ពង្វាងការពិត ក្លែងបន្លំ ឬធ្វើឱ្យមានការភ័ន្តច្រឡំអំពីគុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវាដែលទាក់ទងនឹង ប្រសិទ្ធភាពមុខនាទី អត្តសញ្ញាណ យថាប្រភេទ ប្រភព គុណភាពខាងរូបធាតុ ឬខាងទ្រង់ទ្រាយរាងកាយ ធាតុផ្សំបរិមាណ របៀប និងកាលបរិច្ឆេទនៃការផលិត ឬ កាលបរិច្ឆេទផុតកំណត់ប្រើប្រាស់វិធី និងលក្ខខណ្ឌនៃការប្រើប្រាស់ មិនត្រូវអនុញ្ញាតទេ។

ក្នុងវិស័យខ្លះ ច្បាប់មិនអនុញ្ញាតឲ្យធ្វើការផ្សាយពាណិជ្ជកម្មទេ។ មាត្រា ១២ នៃច្បាប់ ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ២០០២ *ហាមដាច់ខាតរាល់ការឃោសនា ឬការផ្សព្វផ្សាយពាណិជ្ជកម្មដែលអះអាងពីការព្យាបាលព្រមទាំងវិធីបង្ការមេរោគអេដស៍/ជំងឺអេដស៍* រីឯច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា និង សរីរាង្គមនុស្ស ២០១៦ មាត្រា ១៧ ចែងថា៖ *ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មទាក់ទងនឹងការទិញ លក់សេរីរាង្គមនុស្ស ត្រូវហាមឃាត់ជាដាច់ខាត*។

ចុះប្រសិនមានបំពាន អ្នកឃោសនា មានទោសដែរឬទេ? ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា **១២** នៃច្បាប់ប្រយុទ្ធការរីករាលដាល មេរោគអេដស៍ ត្រូវពិន័យជាប្រាក់ពី ៥០០ ០០០ (ប្រាំសែន) រៀលដល់ ១ ០០០ ០០០ (មួយលាន) រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែដល់ ១ (មួយ) ឆ្នាំ។ ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។ រីឯមន្ត្រីរាជការ ត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល (មាត្រា ៤៨)។ បើបំពានមាត្រា ១៧ នៃច្បាប់ បរិច្ចាគសរីរាង្គ នឹងទទួលទោស ពី៥ ទៅ ១០ ឆ្នាំ ក្នុងពន្ធនាគារ (មាត្រា ២៤)។

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និង មាត្រា ១២ នៃច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ ឆ្នាំ ២០១៩ (មិនសុចរិតពាក់ព័ន្ធ នឹងទំនិញ សេវា ឬការអះអាងដោយបំភាន់) ទទួលពិន័យ ២០ លានរៀល (មាត្រា ៤១) ។ បើការអះអាងបំភាន់ នាំឲ្យមាន ពិការភាព ឬមរណភាព

ដោយសារការប្រើប្រាស់ផលិតផល...ទទួលទោសពន្ធនាគារ ពី ២ ទៅ៥ ឆ្នាំ និងពិន័យរហូតដល់ ១០ លានរៀល (មាត្រា ៤៣)។

**<u>កំណត់សំគាល់</u>**៖ ជាសរុប អាជីវករ មានសិទ្ធិធ្វើការផ្សាយពាណិជ្ជកម្ម ដើម្បីទាក់ទាញ អតិថិជន ក៏ប៉ុន្តែ ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ កុំបំប៉ោង ឬភូតកុហក ដើម្បីកុំឲ្យអ្នកប្រើប្រាស់ ឬទទួលសេវា ភាន់ច្រឡំ ចំណាយលុយទិញផលិតផលខុស ខាតពេលវេលា ឬជួនកាលនាំឲ្យប៉ះពាល់ដល់សុខភាពអតិថិជន។ នោះ ជាពិសេស ហានីភ័យនឹងកើតមានចំពោះ ប្រជាពលរដ្ឋក្រីក្រ ដែលខ្វះចំណេះដឹងក្នុងការពិចារណា។ នេះ ជាមូលហេតុ នៃវត្តមានរបស់ច្បាប់ទាំងនេះ ដែលចង្អុលបង្ហាញ ឲ្យអ្នកធ្វើអាជីវកម្មឲ្យបានត្រឹមត្រូវ ស្របពេល គ្នានេះ ការពារផលប្រយោជន៍អ្នកប្រើប្រាស់។ អាស្រ័យហេតុនេះ ជាគុណធម៌ និងសីលធម៌ អ្នកផ្សាយ ឬលក់ផលិតផល ត្រូវគោរពច្បាប់ ប្រសិនមិនដូចនេះទេ ពួកគេនឹងទទួលទោស តាមច្បាប់ដូចដែលបានដក ស្រង់ខាងលើ។